# ពៀរអាចរំងាប់បានដោយការមិនចងពៀរ

អត្ថបទការផ្សះផ្សានៅកម្ពុជាដែលសរសេរដោយអ្នកស្រី ស៊ូហ្សាណា លីនតុន ជាប្រធានរឿងមួយដ៏ធំធេងណាស់សម្រាប់ស្តារនិងកសាងកម្ពុជាឲ្យមានសុវត្ថិភាព ។ ខ្ញុំសូមគោរពចំពោះ អ្នកស្រី ស៊ូហ្សាណា លីនតុន ដែលបានធ្វើវិភាគជុំវិញអត្ថបទនេះតាមគោលការណ៍លទ្ធិប្រជាធិបតេយ្យ នីតិវិធីយុត្តិធម៌ ធម្មា-ធិបតេយ្យ រួមផ្សំនឹងទ្រឹស្តីព្រះពុទ្ធ «ពៀរអាចរំងាប់បានដោយការមិនចងពៀរ» ដោយតម្រូវដោះស្រាយតាមរយៈតុលាការជាតិ និងអន្តរជាតិជូនជនរួមជាតិនូវសេចក្តីថ្លៃថ្នូរដែលប្រជារាស្ត្រទូទៅប្រាថ្នាចង់បានដែលកន្លងមកកម្រមានវរជនណាយកមធ្យោបាយនេះមកប្រើប្រាស់ក្នុងការអប់រំ ផ្សះផ្សា និងការកសាងសង្គមខ្មែរ ។ ជាអកុសល មេដឹកនាំនយោបាយខ្មែរមិនដែលយកវិធីបែបនេះមកអប់រំក្នុងជួរនយោបាយទេ ។ ជាទូទៅអ្នកនយោបាយខ្មែរតែងតែអះអាងថាខ្លួនជាអ្នកស្នេហាជាតិ ដើរអំពាវនាវប្រមូលកម្លាំងឲ្យគាំទ្រខ្លួនដើម្បីការពារទឹកដីនិងជាតិសាសន៍ បំពាក់បំប៉នកំហឹងហិង្សាសងសឹកដោយកម្លាំងបាយ ។ នៅទីបញ្ចប់ លទ្ធផលដែលបានមកគឺៈ ១) បានត្រឹមតែបម្រើប្រយោជន៍បុគ្គលដែលលោភលន់អំណាចនិងបំប៉នតណ្ហាពោរពេញដោយលោភៈទោសៈ ។ ២) ប្រទេសជាតិទទួលបានតែការបាត់បង់កាន់តែធ្ងន់ថែមទៀត ។ ប្រជារាស្ត្របាក់បែក គ្មានសន្តិសុខ ប្រកាន់យកទ្រឹស្តីខុសគ្នា ហើយបង្ក្រាបគ្នាទៅវិញទៅមកដោយប្រើកម្លាំងហិង្សា ជាកត្តានាំឲ្យហ៊ានសម្លាប់កម្ទេចពូជសាសន៍ឯង គ្រួសារឯង បំផ្លាញទ្រព្យសម្បត្តិជាតិ ប្រទេសជាតិ ដែលពិបាកនិងជឿបាន ។ ទោះបីនៅសម័យនេះមានជនដៃដល់ដែលធ្លាប់បានប្រព្រឹត្តអំពើយង់ឃ្នងលើពូជសាសន៍ឯងមួយចំនួនបានសរសេរអត្ថបទរបស់ខ្លួនដោយសារភាពទាំងវិប្បដិសារីតាមរយៈសៀវភៅស្វែងរកការពិត យ៉ាងណាក៏ដោយ ក៏នៅតែមានមនុស្សមួយចំនួននិងមេដឹកនាំខ្លះ

នៅតែមិនព្រមសារភាពអំពើយង់ឃ្នងដែលខ្លួនបានអនុវត្តមមកលើប្រទេសជាតិដែរ ហើយបន្តឃោសនាថា អំពើឃាដកម្មជំនាន់នោះគឺជាយួនទេដែលជាអ្នកប្រព្រឹត្ត "វាចូលមកសម្លាប់ ហើយធ្វើជាចូលមកជួយជានយោបាយចង់បានទឹកដី" ។

ព្រះពុទ្ធបានសម្តែងថា "មនុស្សគ្រប់រូបត្រូវតែប្រឈមមុខទទួលកម្មផលដែលខ្លួនបានប្រព្រឹត្ត" ។ ការស្វែងរកយុត្តិធម៌ជូនជនរងគ្រោះតាមរយៈតុលាការជាតិនិងអន្តរជាតិបានផ្តល់នូវក្តីអំណរឥតឧបមាដល់ប្រជារាស្ត្រទន់ខ្សោយដែលអាចរំងាប់អារម្មណ៍ឈឺចាប់របស់ខ្លួន និងបន្តជីវិតរស់នៅឲ្យបានសុខសាន្តទៅអនាគត ។ សុភាសិតបារាំងមួយបានចែងថា "គំនិតរបស់អ្នកខ្លាំងតែងតែត្រូវជានិច្ច" (*La raison du plus fort est toujours la meilleure*) ទន្ទឹមគ្នានឹងអ្នកដែលខំធ្វើការស្វែងរកយុត្តិធម៌ជូនជនរួមជាតិ អ្នកនយោបាយមួយចំនួនក៏ខំឃោសនា បំពាក់បំប៉ន គោលជំហរប្រកាន់យកគំនិតបដិសេធថា មិនមែនខ្មែរក្រហមទេដែលប្រព្រឹត្តឧក្រិដ្ឋកម្មនេះជាល្បិចរបស់យួនទេ ចូររួមគ្នាឡើងដើម្បីការពារទឹកដី ។ ដូច្នេះគួរតែប្រយ័ត្នការឃោសនានៃអ្នកនយោបាយខ្លះដែលអះអាងថាខ្លួនស្នេហាជាតិ ស្អាតស្អំ រិះគន់អំពើពុករលួយជាលេសមួយក្នុងល្បិចកលឲ្យអ្នកផងគាំទ្រខ្លួនដើម្បីឆាឆៅក្នុងន័យដុតឲ្យខ្លោចរោចឲ្យឆៅ មិនឲ្យលទ្ធិប្រជាធិបតេយ្យសិទ្ធិមនុស្សលូតលាស់បាន ។ ឧទាហរណ៍ កាលជំនាន់មុនឆ្នាំ១៩៧០ លោកខៀវ សំផន បានឃោសនាទូទាំងប្រទេសថា ខ្លួនជាអ្នកស្នេហាជាតិជាបុគ្គលស្អាតស្អំ ស្មោះត្រង់នឹងជាតិ មិនលក់ខ្លួនឲ្យបរទេស តែដល់ខ្លួនគាត់កាន់អំណាចវិញ គាត់ដេញប្រជាជនឲ្យចុះចេញពីផ្ទះតែខ្លួនទទេ ហើយយកទ្រព្យសម្បត្តិរបស់ជាតិនិងប្រជាជនតាមអំពើចិត្ត ។ ទាំងអស់គ្នាសុទ្ធតែអះអាងថាជាអ្នកស្នេហាជាតិ តាំងពីប្រជារាស្ត្រតូចតាចរហូតដល់មេដឹកនាំកំពូល ។ ពេលចូលប្រឡូកក្នុងជួរនយោបាយ ម្នាក់ៗពុំមានការស្មោះត្រង់ជាតិនិងប្រជារាស្ត្រទេ គិតតែធ្វើយ៉ាងណាតម្រូវចិត្តមហាអំណាចបរទេស មហាអំណាចនេះមហាអំណាចនោះ ហើយសុំឲ្យមហាអំណាចទាំងនោះជួយតែកាំភ្លើងយកមកសម្លាប់គ្នាទៅវិញទៅមកដើម្បីការពារខ្លួនក្នុងអត្តចរិតមហិច្ឆតាលោភលន់អំណាចផ្ទាល់ខ្លួនតែប៉ុណ្ណោះ ។ ដូច្នេះមុននឹងសម្រេចចិត្តគាំទ្រមេដឹកនាំនយោបាយណាមួយ ចូរធ្វើការពិចារណាឲ្យបានល្អិតល្អន់ពីគុណសម្បត្តិនិងគុណវិបត្តិនៃបុគ្គលនោះ មិនមែនគ្រាន់តែអះអាងថាខ្លួនស្នេហាជាតិស្អាតស្អំជាការគ្រប់គ្រាន់នោះទេ ។ ត្រូវស្វែងរកការពិតមួយថាតើបុគ្គលនោះមានសមត្ថភាពកសាងជាតិឬទេ និងដោយរបៀបណា?

បងប្អូនរួមជាតិជាទីស្នេហា ចូរចាប់អារម្មណ៍ក្នុងសម័យបច្ចុប្បន្ននេះ ប្រទេសជាតិយើងមានភ័ព្វវាសនាទទួលបាននូវមាគ៌ាលទ្ធិប្រជាធិបតេយ្យ ជារបបមួយដែលផ្តល់សិទ្ធិឲ្យប្រជារាស្ត្រជាធំ ដែលកន្លងមកមិនធ្លាប់បានយកមកអនុវត្តនៅប្រទេសយើងទេ ។ ប្រជារាស្ត្រគ្រប់រូបគួរតែនាំគ្នាសិក្សាអំពីលទ្ធិប្រជាធិបតេយ្យនេះឲ្យបានចេះដឹងជ្រៅជ្រះដើម្បីយកទៅអនុវត្តឲ្យបានសមស្របទៅនឹងបំណងកសាងប្រទេសជាតិ ឈានទៅកាន់ការអភិវឌ្ឍជឿនលឿន កុំឲ្យចាញ់ប្រទេសជាតិខាង ។ ជាកម្លាំងពង្រឹងស្មារតីការពារប្រទេសជាតិ និងទឹកដី ។

**ហ៊ីង ឃីង**

## ស្តាប់រឿងរ៉ាវប្រវត្តិសាស្ត្រតាមវិទ្យុ

មជ្ឈមណ្ឌលឯកសារកម្ពុជាបានបង្កើតឲ្យមានកម្មវិធីអានអត្ថបទទស្សនាវដ្តីស្វែងរកការពិតដែលចាក់ផ្សាយរៀងរាល់ថ្ងៃពុធនិងព្រហស្បតិ៍ វេលាម៉ោង៣ៈ៣០-៣ៈ៤៥នាទី តាមរយៈវិទ្យុ FM១០២ MHz របស់មណ្ឌលព័ត៌មានស្ត្រីកម្ពុជា ។

មជ្ឈមណ្ឌលក៏បានបង្កើតកម្មវិធីដូចគ្នានេះផ្សាយតាមស្ថានីយ៍វិទ្យុ FM៩៣.២៥MHz ខេត្តកំពតជារៀងរាល់ថ្ងៃនៅម៉ោង៧-៧ៈ៣០នាទីព្រឹក និងម៉ោង៧-៧ៈ៣០នាទីល្ងាចនិងស្ថានីយ៍វិទ្យុ FM៩៩MHz ខេត្តព្រះវិហារ នៅម៉ោង៧-៧ៈ៣០នាទីព្រឹក និងម៉ោង៦ៈ៣០-៧នាទីល្ងាច ។

នៅក្នុងពេលដ៏ខ្លីខាងមុខនេះ មជ្ឈមណ្ឌលឯកសារកម្ពុជានឹងផ្សាយកម្មវិធីដូចគ្នានេះនៅគ្រប់បណ្តាស្ថានីយ៍វិទ្យុខេត្តនៃព្រះរាជាណាចក្រកម្ពុជា ។

យើងខ្ញុំសង្ឃឹមថា កម្មវិធីនេះនឹងចូលរួមចំណែកក្នុងការផ្តល់ឱកាសឲ្យប្រជាជនកម្ពុជាស្វែងយល់អំពីប្រវត្តិសាស្ត្រនៃរបបខ្មែរក្រហម និងទប់ស្កាត់ការកើតមានឡើងវិញនៃរបបនេះ ។

**លី សុផល និង សូ ហ្វារីណា**